FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# ការស្ទូងស្រូវដោយដៃ

**អ្វីទៅជាការស្ទូងស្រូវ ?**

ការធ្វើស្រែនៅតំបន់អាស៊ី ការស្ទូងស្រូវដោយដៃជាវិធីសាស្ត្រដ៏សាមញ្ញបំផុត ។ សំណាបដែលសាបនៅក្នុងកូនស្រែមួយស្អាតល្អ បន្ទាប់ពីមានអាយុកាលពី ១៥-៤០ថ្ងៃ ត្រូវបានគេដក និងជញ្ជូនទៅដាក់នៅក្នុងដីស្រែដែលបានភ្ជួររាស់ និងធ្វើដីបានរាបស្មើល្អ ។ នៅក្នុងតំបន់មួយចំនួនរបស់ប្រទេសចិនមានការអនុវត្តន៍ព្រោះសំណាប។

**អ្វីទៅជាការស្ទូងស្រូវដោយដៃ ?**

ការស្ទូងស្រូវដោយដៃ គឺយើងមិនត្រូវការម៉ាស៊ីនមានតម្លៃថ្លៃ ហើយវាសមស្របបំផុតចំពោះតំបន់ណាដែលមានកម្លាំងពលកម្មលើស និងសម្រាប់ដីស្រែណាដែលមានទំហំតូចល្មមប៉ុណ្ណោះ ។ ការស្ទូងដោយដៃអាចធ្វើបាននៅក្នុងស្រែដែលដីមិនរាបស្មើ និងកម្ពស់ទឹកក្នុងស្រែមិនស្មើគ្នា ។ ការសាបសំណាបត្រូវគេធ្វើនៅក្នុងកូនស្រែស្អាតដែលមានដីសើម ស្ងួត ឬ ក៏ជាថ្នាលសំណាប។ ការគ្រប់គ្រងកូនស្រែសាបសំណាបបានត្រឹមត្រូវ យើងនឹងទទួលបានសំណាបដែលមានសុខភាពល្អ និងកម្លាំងមាំមួន ។

**ហេតុអ្វីបានត្រូវស្ទូងស្រូវ ?**

ការស្ទូងធានាបាននូវដើមស្រូវដុះស្មើគ្នា និងធ្វើឱ្យស្រូវលូតលាស់លឿនជាងស្មៅ ព្រមទាំងមិនឱ្យស្មៅលូតលាស់បានទៀតផង។ ការស្ទូងអាចធ្វើឱ្យស្រូវមានលក្ខណៈខ្លាំងក្លា ក្នុងរយៈពេលខ្លីមួយដូចជាស្រូវដែលដាំនៅក្នុងដីស្រែល្អមួយដែរ ។

ធ្វើដូចម្តេចដើម្បីស្ទូងស្រូវដោយដៃ ?

១- ដកសំណាបពីក្នុងកូនស្រែសាបនៅពេលដែលវាមានអាយុកាលចាប់ពី ១៥-៣០ថ្ងៃ រួចជញ្ជូនវាដាក់ក្នុងស្រែដែលត្រូវស្ទូង

២- នៅក្នុងកូនស្រែ ឬថ្នាលសំណាប អាយុកាលរបស់សំណាបពី ១៥-២០ថ្ងៃ គឺសមស្របសម្រាប់យកទៅស្ទូង

៣- បន្ទាប់ពីដកសំណាបចេញពីថ្នាលរួច ត្រូវស្ទូងសំណាបនោះភ្លាមដែរនៅក្នុងដីស្រែដែលបានភ្ជួររាស់ និងពង្រាបបានល្អ (បើយើងពន្យារពេលស្ទូង សំណាបនោះនឹងមិនងាយដឹងខ្លួន ឬក៏អាចបណ្ដាលឱ្យងាប់) ។

៤- ស្ទូងក្នុង ១គុម្ព ពី ២-៣ដើម ក្នុងជម្រៅរាក់ល្មម ដោយមានចន្លោះគុម្ពសមស្រប ២០សង្ទីម៉ែត្រ x ២០សង្ទីម៉ែត្រ ឬ ២២,៥ សង្ទីម៉ែត្រ x ២២,៥ សង្ទីម៉ែត្រ ។

៥- ជញ្ជូនសំណាបដោយប្រុងប្រយ័ត្នដើម្បីធានាបានថា សំណាបទាំងនោះនឹងឆាប់ដឹងខ្លួន ហើយលូតលាស់ឆាប់រហ័ស បន្ទាប់ពីបានស្ទូងរួចភ្លាម ។

**កត្តាកំណត់ផ្សេងៗ**

- ការស្ទូងស្រូវវាមានការនឿយហត់ខ្លាំងនិងចំណាយពេលព្រមទាំងកម្លាំងពលកម្មច្រើន (៣០នាក់ ក្នុង ១ថ្ងៃ ក្នុង១ ហិកតា) ។
- អ្នកស្ទូងស្រូវអាចទទួលរងការឈឺខ្នង (គ្រោះថ្នាក់ដល់សុខភាព)
- ពិបាករកកម្លាំងឱ្យបានគ្រប់គ្រាន់ ដើម្បីស្ទូងបានទាន់ពេលវេលាកំណត់
- ពិបាករក្សាចន្លោះគុម្ពសមស្របឱ្យត្រង់ជួរ ដង់ស៊ីតេស្រូវស្មើគ្នា
- គ្រោះថ្នាក់នៅក្នុងតំបន់គ្មានភ្លៀងធ្លាក់ដែលសំណាប (ពិសេស ចំពោះពូជស្រូវទំនើប) អាចមានអាយុកាលចាស់ជ្រុលមុនពេលដែលមានភ្លៀងធ្លាក់ និងដីស្រែត្រូវបានធ្វើ និងដាំដុះរួចស្រេចបាច់ហើយនោះ ។



រូបភាព ការដកសំណាបដែលមានអាយុ កាលពី ២០-៣០ថ្ងៃ តាមបែបបុរាណ



រូបភាពសំណាបដែលមានអាយុកាលពី ១៥-២០ថ្ងៃ នៅក្នុងកូនថ្នាលសាប



រូបភាពការស្ទូងស្រូវនៅក្នុងដីស្រែដែល បានភ្ជួររាស់និងពង្រាបដីបានល្អ



រូបជញ្ជូនសំណាបដោយប្រុងប្រយត្ន័